# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅស្វាយប៉ាក
# ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៩
# តើអ្នកស្រឡាញ់ខ្ញុំទេឬ?

**អត្ថបទទី១៖ កិច្ចការ ៥,២៧ខ-៣២.៤០ខ-៤១**
យើងខ្ញុំជាសាក្សីអំពីហេតុការណ៍ទាំងនេះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះជាម្ចាស់ប្រទានដល់អស់អ្នកស្ដាប់បង្គាប់ព្រះអង្គ ទ្រង់ក៏ជាសាក្សីដែរ។ កក ៥,៣២

**អត្ថបទទី២៖ វិវរណៈ ៥,១១-១៤**
នាំគ្នាបន្លឺសំឡេងឡើងយ៉ាងខ្លាំងៗថា: «កូនចៀមដែលគេសម្លាប់ធ្វើយញ្ញបូជា ទ្រង់សមនឹងទទួលឫទ្ធានុភាព រាជសម្បត្តិ ព្រះប្រាជ្ញាញាណ ឥទ្ធិឫទ្ធិ ព្រះកិត្តិនាម សិរីរុងរឿង និងការសរសើរតម្កើង»។ វវ ៥,១២

**ដំណឹងល្អ៖ យ៉ូហាន ២១,១-១៩**
ព្រះយេស៊ូមានព្រះបន្ទូលសួរលោកស៊ីម៉ូនស៊ីម៉ូនសិលាថា៖ «ស៊ីម៉ូន កូនលោកយ៉ូហានអើយ! តើអ្នកស្រឡាញ់ខ្ញុំ ជាងអ្នកទាំងនេះស្រឡាញ់ខ្ញុំឬ?»។ យហ ២១,១៥

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថបទទី១ យើងបានស្ដាប់ ពេលគេបានហៅលោកសិលានិងគ្រីស្ដទូតឯទៀតៗ ដើម្បីកាត់ក្ដីពួកគាត់ ដោយសារពួកគាត់កំពុងប្រកាសអំពីព្រះយេស៊ូ។ មានពួកធម្មជាចារ្យ ក្រុមប្រឹក្សាជាន់ខ្ពស់ បានហាមពួកគាត់មិនឲ្យនិយាយអំពីព្រះយេស៊ូ ក្រោយមកក្រុមគ្រីស្ដទូតបានឆ្លើយថា "**យើងត្រូវស្ដាប់បង្គាប់ព្រះជាម្ចាស់ ជាជាងស្ដាប់បង្គាប់មនុស្ស**"។ សម្រាប់យើងជាគ្រីស្ដបរិស័ទ ឲ្យយើងធ្វើដូចម្ដេចដើម្បីស្ដាប់ពិចារណា ពីបង្គាប់ដែលមកពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ដឹកនាំយើង ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះជាម្ចាស់ណែនាំឲ្យយើងជាគ្រីស្ដបរិស័ទអាចរស់នៅជាគ្រីស្ដបរិស័ទពិតមែន។ ប្រសិនបើយើងស្ដាប់បង្គាប់របស់មនុស្ស យើងភ្លេចព្រះជាម្ចាស់ យើងមិនមែនជាគ្រីស្ដបរិស័ទដ៏ពេញលក្ខណ:។

ក្រុមគ្រីស្ដទូតបានផ្ដល់សក្ខីភាពអំពីព្រះយេស៊ូ ដែលជាព្រះអង្គម្ចាស់ ដែលយាងមកដើម្បីសង្គ្រោះមនុស្ស ដែលព្រះជន្មរស់ឡើងវិញ ដែលគង់នៅសព្វថ្ងៃ។ នៅពេលក្រុមប្រឹក្សាជាន់ខ្ពស់បានហាមគេ ប៉ុន្តែគេមិនបានភ័យ មិនបានខ្លាចអ្វីទេ "**ក្រុមគ្រីស្ដទូតបានចាកចេញពីក្រុមប្រឹក្សាជាន់ខ្ពស់ទាំងអរសប្បាយ**"។ គេសប្បាយដោយសារ គេបានផ្ដល់សក្ខីភាពអំពីព្រះយេស៊ូ គេបាន

យល់ថាព្រះយេស៊ូជាអាទិភាពនៃជីវិតរបស់គេ។ **តើព្រះយេស៊ូជាអាទិភាពនៃជីវិតរបស់យើងដែរឬទេ? តើយើងស្រឡាញ់ព្រះយេស៊ូដល់កម្រិតណា?**

នៅស្វាយប៉ាកសព្វថ្ងៃ ប្លែកណាស់យើងមានការអភិវឌ្ឍលឿនណាស់ អ្វីៗទាំងអស់ប្រែប្រួល ប៉ុន្តែ**តើយើងប្រែប្រួលឬទេ?** ព្រះយេស៊ូមិនដែលប្រែប្រួលទេ តែមនុស្សយើងកែ។ ប៉ុន្តែ អ្វីដែលសំខាន់គឺសក្ខីភាពដែលយើងផ្តល់ **តើជាសក្ខីភាពដែលស្ថិតស្ថេរជានិច្ចឬទេ?** នៅមុខព្រះវិហារយើងមានសាលាមួយរបស់ប្រូតេស្តង់ ឈ្មោះ អែម (AIM SCHOOL) ប្រែថា មេត្តាករុណានៅក្នុងការប្រកាសដំណឹងល្អ។ យើងមាននិកាយផ្សេងៗគ្នានៅទល់មុខគ្នា នេះអាចទៅជាកម្លាំងមួយសម្រាប់យើងថែមទៀត **តើខ្ញុំដែលជាសាវ័ករបស់ព្រះយេស៊ូនៅស្វាយប៉ាកនេះ ខ្ញុំប្រកាសដំណឹងល្អនៅក្នុងធម៌មេត្តាករុណារបស់ព្រះអង្គដូចម្តេច?** គម្ពីរដំណឹងល្អថ្ងៃនេះ សំណួររបស់ព្រះយេស៊ូទៅលោកសិលា "**តើអ្នកស្រឡាញ់ខ្ញុំទេឬ?**" ព្រះអង្គបានសួរលោកសិលាបីដង ប្រហែលណែនាំឲ្យលោកសិលានឹកឃើញដែរ ថាគាត់បានបដិសេធថាមិនស្គាល់ព្រះអង្គបីដងដែរ។ នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ គឺស្រឡាញ់ព្រះយេស៊ូ **តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យសេចក្តីស្រឡាញ់ដែលយើងមានចំពោះព្រះយេស៊ូអាចទៅដល់បងប្អូនឯទៀតៗបាន? តើយើងធ្វើយ៉ាងម៉េចឲ្យធម៌មេត្តាករុណារបស់ព្រះអង្គ ដែលមានព្រះហឫទ័យអាណិតមេត្តា ដែលមានព្រះហឫទ័យស្រឡាញ់ អាចទៅដល់បងប្អូនឯទៀតៗ?** ពេលយើងចង់បង្ហាញធម៌មេត្តាករុណា **តើយើងត្រូវការធ្វើអ្វីខ្លះ?** ប្រកាសដំណឹងល្អ ដោយសម្តែងធម៌មេត្តាករុណារបស់ព្រះអង្គដល់កំពូល គឺណែនាំឲ្យបងប្អូនឯទៀតៗស្គាល់និងស្រឡាញ់ព្រះយេស៊ូ។

នេះជាអាទិភាពនៃការប្រកាសដំណឹងល្អ ណែនាំឲ្យបងប្អូនឯទៀតៗស្តាប់ឮ ស្គាល់ និងស្រឡាញ់ព្រះយេស៊ូ។ នេះហើយយើងត្រូវតែអនុវត្ត ប្រសិនបើការប្រកាសដំណឹងល្អរបស់យើងតែលើបបូរមាត់ទៅមិនរួចទេ ឲ្យយើងជាគ្រីស្តបរិស័ទយកចិត្តទុកដាក់ចូលអភិបូជាជារៀងរាល់សប្តាហ៍ យកចិត្តទុកដាក់សូត្រធម៌ យកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ធ្វើដូចម្តេចដើម្បីឲ្យយើងមានស្នាដៃនៃធម៌មេត្តាករុណា ដើម្បីឲ្យយើងប្រកាសដំណឹងល្អនៅក្នុងធម៌មេត្តាករុណា។ ធម៌មេត្តាករុណារបស់ព្រះយេស៊ូ ឲ្យយើងអនុវត្តនៅក្នុងជីវិតរបស់យើងផ្ទាល់ យើងត្រូវស្តាប់បង្គាប់ព្រះអង្គម្ចាស់ និងឲ្យយើងមានអំណរសប្បាយនៅពេលយើងប្រកាសដំណឹងល្អ។ ទោះបីគេរិះគន់ គេមើលងាយ គេហាម តែយើងមានអំណរសប្បាយ ដោយសារយើងដឹងថាយើងបានបំពេញតួនាទីយើងជាគ្រីស្តទូត ជាសាវ័ក ជាមិត្តសម្លាញ់របស់ព្រះគ្រីស្ត។ មួយទៀត ឲ្យយើងស្តាប់សំណួររបស់ព្រះយេស៊ូមានចំពោះលោកសិលា "**តើអ្នកស្រឡាញ់ខ្ញុំទេឬ?**" បើយើងឆ្លើយថាខ្ញុំស្រឡាញ់ **តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ**

**យេស៊ូ ដល់បងប្អូនឯទៀតៗ ដល់ព្រះសហគមន៍របស់យើង ដល់សង្គមរបស់យើង ដល់ប្រជាជនរបស់យើងដែលមិនទាន់ស្គាល់ព្រះយេស៊ូ?**

តើយើងធ្វើដូចម្តេច ដើម្បីបង្កើតទំនាក់ទំនងជាមួយប្រូតេស្តង់? យើងពូកែធ្វើអន្តរសាសនា តែយើងមិនដែលធ្វើអន្តរនិកាយទេ។ មានន័យថា នៅក្នុងអ្នកដែលជឿលើព្រះយេស៊ូដូចគ្នា នៅទីនេះយើងនៅទល់មុខគ្នា **តើយើងធ្វើដូចម្តេចដើម្បីឲ្យយើងស្រឡាញ់ព្រះយេស៊ូតែមួយ?** ឲ្យយើងបង្កើតទំនាក់ទំនងជាមួយប្រូតេស្តង់និងកាតូលិក ដោយបង្ហាញថាមានព្រះយេស៊ូតែមួយពិតមែន មានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់តែមួយពិតមែន។ យ៉ាងតិចឲ្យយើងមានកម្មវិធីខ្លះៗជាមួយគ្នា ដូចជាអានគម្ពីរ ចែករំលែកគម្ពីរជាមួយគ្នា...។ ឲ្យយើងបង្កើតទំនាក់ទំនង ដើម្បីបង្ហាញសេចក្តីស្រឡាញ់តែមួយដែលយើងបានទទួលពីព្រះជាម្ចាស់ ស្តាប់បង្គាប់ព្រះជាម្ចាស់ពោរពេញដោយអំណរសប្បាយពេលយើងប្រកាសដំណឹងល្អ និងស្រឡាញ់ដោយស្តាប់សំណួររបស់ព្រះយេស៊ូ "**តើអ្នកស្រឡាញ់ទេឬ?**"។ អាម៉ែន៕